*ប្រព័ន្ធការពារ និងតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*
*លេខទូរស័ព្ទហៅមិនអស់ប្រាក់ (800) 776-5746*

# ឯកសារការពិតអំពីជម្រើស និងដំណើរការ ប្ដឹងឧទ្ធរណ៍របស់ក្រសួងស្ដានីតិសម្បទារដ្ឋកាលីហ្វ័រនីញ៉ា

***ខែវិច្ឆិកា ឆ្នាំ 2013 អត្ថបទបោះពុម្ពផ្សាយលេខ 5530.06***

## 1. តើខ្ញុំត្រូវធ្វើអ្វីទៀត បើខ្ញុំមានបញ្ហាជាមួយនឹងអ្នកប្រឹក្សាយោបល់របស់ខ្ញុំដែលមកពីនាយកដ្ឋានស្ដានីតិសម្បទា (DOR, Department of Rehabilitation)?

ជំហានដំបូងរបស់អ្នក គឺត្រូវព្យាយាមដោះស្រាយបញ្ហាដែលកើតឡើងជាមួយនឹងអ្នកប្រឹក្សាយោបល់ DOR របស់អ្នក ។ បើអ្នកមិនអាចដោះស្រាយបញ្ហានេះជាមួយអ្នកផ្ដល់យោបល់របស់អ្នកបានទេ ត្រូវស្នើសុំប្រជុំជាមួយនឹងអ្នកគ្រប់គ្រងរបស់អ្នកផ្ដល់ការប្រឹក្សាយោបល់ ។ អ្នកគ្រប់គ្រងផ្នែកស្ដានីតិសម្បទា (Rehabilitation Supervisor) អាចជួយអ្នកដោះស្រាយបញ្ហាបាន ។ បើអ្នកមិនពេញចិត្តចំពោះសកម្មភាពរបស់ DOR ទេ អ្នកមានសិទ្ធិប្ដឹងឧទ្ធរណ៍ ។

## 2. តើខ្ញុំមានជម្រើសអ្វីខ្លះក្នុងការប្ដឹងឧទ្ធរណ៍?

គឺអ្នកមានជម្រើសមួយចំនួន ចំពោះការប្ដឹងឧទ្ធរណ៍ អ្នកអាចស្នើសុំការពិនិត្យបញ្ហាឡើងវិញជាលក្ខណៈរដ្ឋបាល ការសម្រុះសម្រួល ឬសវនាការយុត្តិធម៌ ។ ជម្រើសដំណោះស្រាយទាំងអស់នេះ នឹងមានពន្យល់ជាលំអិត ខាងក្រោម ។

## 3. តើខ្ញុំអាចស្នើសុំការពិនិត្យសំណុំរឿងតាមបែបរដ្ឋបាលដោយវិធីណា?

ការពិនិត្យសំណុំរឿងឡើងវិញតាមលក្ខណៈរដ្ឋបាល គឺជាវិធីរកដំណោះស្រាយក្នុងកម្រិតទាបបំផុត ។ ប្រសិនបើក្ដីកង្វល់របស់អ្នក មិនអាចដោះស្រាយបានតាមរយៈអ្នកប្រឹក្សាយោបល់ DOR របស់អ្នក ឬប្រធានផ្នែកស្ដានីតិសម្បទាក្នុងកម្រិតមូលដ្ឋានបានទេ អ្នកអាចស្នើសុំឲ្យមាន
ការពិនិត្យសំណុំរឿងរបស់អ្នកឡើងវិញតាមលក្ខណៈរដ្ឋបាល ដែលត្រូវធ្វើឡើងដោយរដ្ឋបាលឌីស្ទ្រិក ។ អ្នកត្រូវស្នើសុំការពិនិត្យសំណុំរឿងឡើងវិញតាមបែបរដ្ឋបាល ក្នុងរវាងមួយឆ្នាំចំពោះការសម្រេចណាមួយដែលអ្នកមិនពេញចិត្ត ។ សំណើសុំរបស់អ្នក ត្រូវរួមបញ្ចូលនូវ ៖

- មូលហេតុដែលអ្នកគិតថាត្រូវប្តូរការសម្រេចចិត្ត និង
- សកម្មភាពអ្វីដែលអ្នកស្នើឲ្យ DOR អនុវត្ត ។

ច្បាប់ Title  9 CCR §7353(a)(3)(A)-(B) ។

## 4. តើនឹងមានអ្វីកើតឡើងនៅពេលពិនិត្យសំណុំរឿងឡើងវិញតាមលក្ខណៈរដ្ឋបាល?

នៅពេលដែលរដ្ឋបាលឧស្រ្ទិក ទទួលបានសំណើសុំការពិនិត្យសំណុំរឿងឡើងវិញតាមលក្ខណៈរដ្ឋបាល ពួកគេអាចសម្រេចធ្វើការរកប្រជុំពិនិត្យសំណុំរឿងឡើងវិញតាមលក្ខៈរដ្ឋបាល ដែលពេលនោះអ្នកត្រូវជួបជាមួយនឹងរដ្ឋបាល ឧស្រ្ទិក ដែលគេជាអ្នកទទួលខុសត្រូវរកដំណោះស្រាយជូនអ្នក ។ នៅក្នុងការប្រជុំនេះ គឺអ្នកនឹងមានឱកាសពន្យល់ពីមូលហេតុដែលអ្នកគិតថា សេចក្តី សម្រេចរបស់ DOR មិនមានភាពសមរម្យ ។  អ្នកអាចយកមកជាមួយនូវឯកសារ និងភស្តុតាងផ្សេងៗទៀត ដែលគាំទ្រជំហររបស់អ្នក ។  អ្នកប្រឹក្សាយោបល់ DOR របស់អ្នក ឬប្រធានផ្នែកស្ថានីតិសម្បទា អាចមានវត្តមាននៅក្នុងការពិនិត្យសំណុំរឿងឡើងវិញតាមលក្ខណៈរដ្ឋបាល ដើម្បីពន្យល់អំពីសេចក្តីសម្រេចរបស់ DOR ។

ក្នុងករណីមួយចំនួន រដ្ឋបាលឧស្រ្ទិក អាចធ្វើការពិនិត្យ និងសម្រេច ដោយពិនិត្យមើល “ឯកសារទាំងអស់” ឡើងវិញ ។   ពេលនោះ រដ្ឋបាលឧស្រ្ទិក នឹងពិនិត្យមើលសំណើសុំរបស់អ្នក ការដាក់ពាក្យប្តឹងរបស់អ្នក ព្រមទាំងឯកសារផ្សេងទៀតទាំងអស់ដែលអ្នកបានដាក់ជូន ។ រដ្ឋបាលឧស្រ្ទិក នឹងធ្វើសេចក្តីសម្រេច ដោយផ្អែកលើសំណុំឯកសារទាំងអស់នេះ ។

រដ្ឋបាលឧស្រ្ទិកនឹងសម្រេចថាតើសកម្មភាពរបស់ DOR មានភាពសមរម្យ ដែរ ឬទេ ហើយផ្ញើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរឲ្យអ្នក ក្នុងរវាង 15 ថ្ងៃ គិតចាប់ពីថ្ងៃដែលអ្នកបានស្នើសុំឲ្យមានការពិនិត្យសំណុំរឿងរបស់អ្នកឡើង វិញតាមលក្ខណៈរដ្ឋបាល ។

## 5. តើត្រូវធ្វើដូចម្តេច បើខ្ញុំមិនពេញចិត្តចំពោះសេចក្តីសម្រេច លើការដោះស្រាយសំណុំរឿងតាម លក្ខណៈរដ្ឋបាល?

បើអ្នកមិនពេញចិត្តចំពោះសេចក្តីសម្រេចចំពោះ ការដោះស្រាយសំណុំរឿងតាមបែបរដ្ឋបាលទេ អ្នកអាចស្នើសុំឲ្យមានការសម្រុះសម្រួល និង/ឬ ស្នើសុំសវនាការយុត្តិធម៌ ។ អ្នកត្រូវស្នើសុំឲ្យរកដំណោះស្រាយក្នុងកម្រិតនេះ ***ឲ្យបាន ក្នុងរវាង 30 ថ្ងៃ*** គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចរបស់ការដោះស្រាយសំណុំរឿងតាមបែបរដ្ឋបាល ។ ច្បាប់ Title 9 CCR §7353(f) ។

## 6. តើការពិនិត្យសំណុំរឿងឡើងវិញតាមបែបរដ្ឋបាល ជាអ្វីដែលត្រូវតែធ្វើដោយចៀសមិនបានមែនទេ?

ទេ ។ ដំណើរការពិនិត្យសំណុំរឿងតាមបែបរដ្ឋបាល គឺជាជម្រើស ។ អ្នកអាចរំលងចោលសកម្មភាពដំណោះស្រាយសំណុំរឿងតាមបែបរដ្ឋបាល ហើយ ស្នើសុំភ្លាមៗឲ្យមានសវនាការយុត្តិធម៌ និង/ឬការសម្រុះសម្រួល ។ ច្បាប់ Title 9 CCR §7351(c) ។ ទោះជាយ៉ាងណាក៏ដោយ ក៏រឿងនេះ អាចមានប្រយោជន៍ ដែរក្នុងការរកដំណោះស្រាយដោយឆ្លងកាត់ដំណើរការដោះស្រាយសំណុំរឿង តាមលក្ខណៈរដ្ឋបាលជាមុនសិន មុននឹងស្នើសុំឲ្យមានការសម្រុះសម្រួល ឬសវនាការយុត្តិធម៌ ។ មានបញ្ហាជាច្រើនអាចដោះស្រាយបាននៅលំដាប់មូលដ្ឋាន ដោះស្រាយតាមបែបក្រៅផ្លូវការ ហើយអាចដោះស្រាយបានកាន់តែលឿនតាមរយៈដំណើរការស្វែងរកដំណោះស្រាយសំណុំរឿងតាមបែបរដ្ឋបាល ។

## 7. តើខ្ញុំអាចស្នើសុំការសម្រុះសម្រួលដោយរបៀបណា?

អ្នកត្រូវដាក់ពាក្យស្នើសុំការសម្រុះស្រួលក្នុងរវាងមួយឆ្នាំ គិតចាប់ពីពេលដែលសកម្មភាពដែលអ្នកមិនយល់ស្របជាមួយបានកើតឡើង ។ បើអ្នកទទួលបានសេចក្តីសម្រេចនៃការស្វែងរកដំណោះស្រាយសំណុំរឿងតាមបែបរដ្ឋបាល អ្នកត្រូវស្នើសុំការសម្រុះសម្រួលក្នុងរវាង 30 ថ្ងៃ គិតចាប់ពីថ្ងៃដែលចេញសេចក្តីសម្រេចក្នុងការរកដំណោះស្រាយសំណុំរឿងតាមបែបរដ្ឋបាល ។ ពាក្យស្នើសុំការសម្រុះសម្រួល ត្រូវដាក់ស្នើក្នុងទម្រង់បែបបទ DR 107 ។ អ្នកក៏អាចស្វែង រកទម្រង់បែបបទនេះតាមអនឡាញបានផងដែរ នៅឯ ៖
http://www.rehab.cahwnet.gov/Appeals/FairHearForms.html#DR107 ។

បើភាគីទាំងពីរយល់ព្រមធ្វើការសម្រុះសម្រួល នោះការសម្រុះសម្រួល នឹងត្រូវធ្វើឡើងទៅតាមពេលវេលា និងទីតាំងដែលសមស្រប សម្រាប់គូភាគីទាំងអស់ក្នុងរវាង 25 ថ្ងៃតាមប្រតិទិន គិតចាប់ពីថ្ងៃដែលអ្នកសម្របសម្រួលការសម្រុះសម្រួលទទួលបានលិខិតស្នើសុំ ។ ច្បាប់ Title 9 CCR §7353.6(b)-(c); 34 C.F.R §361.57(d) ។

## 8. តើការសម្រុះសម្រួលជាអ្វីដែលត្រូវតែធ្វើមែនទេ?

ទេ ។ ការសម្រុះសម្រួលក៏ជាជម្រើសផងដែរ ។ 34 C.F.R §361.57(d)(2)(i) ។ អ្នកអាចសម្រេចមិនជ្រើសយកដំណើរការដំណោះស្រាយបញ្ហាតាមការសម្រុះ សម្រួល ហើយយកការធ្វើសវនាការយុត្តិធម៌តែម្តងក៏បានដែរ ។ ក្នុងនេះផងដែរ DOR មិនត្រូវបានតម្រូវឲ្យចូលរួមក្នុងដំណើរការសម្រុះសម្រួលទេ DOR អាចសម្រេចថាពួកគេមិនត្រូវការចូលរួមក្នុងដំណើរការស្វែងរកដំណោះ ស្រាយ សំណុំរឿងតាមការសម្រុះសម្រួល ។ ដូចគ្នាទៅនឹងដំណើរការពិនិត្យសំណុំរឿង

ឡើងវិញតាមបែបរដ្ឋបាលផងដែរ ការសម្រុះសម្រួល វាមិនមែនជាការ ពន្យារសិទ្ធិរបស់អ្នកដើម្បីស្នើសុំសវនាការយុត្តិធម៌ឡើយ ។ ច្បាប់ Title 9 CCR §7353.6(b) ។

## 9. តើមានអ្វីកើតឡើងនៅពេលធ្វើការសម្រុះសម្រួល?

នៅពេលធ្វើការសម្រុះសម្រួល អ្នកនឹងជួបជាមួយអ្នកសម្រុះសម្រួលដែលមិនលំអៀង ព្រមទាំងអ្នកតំណាងមកពី DOR ។ អ្នកសម្រុះសម្រួល នឹងព្យាយាមជួយអ្នក និង DOR ក្នុងការដោះស្រាយវិវាទ ហើយទទួលបានការព្រមព្រៀងគ្នា ។ បើអ្នកដាក់ពាក្យសុំឲ្យមានការសម្រុះសម្រួល និងសវនាការយុត្តិធម៌ ក្នុង ពេលតែមួយ ហើយអ្នកអាចដោះស្រាយវិវាទរបស់អ្នកបានតាមរយៈការសម្រុះ សម្រួល នោះពាក្យសុំសវនាការយុត្តិធម៌ នឹងត្រូវដកចេញវិញ ។

ការសម្រុះសម្រួលវិវាទ គឺជាដំណើរការសម្ងាត់ ។ ត្រង់នេះគឺមានន័យថា ព័ត៌មានទាំងឡាយណាដែលត្រូវបានលើកឡើងក្នុងពេលធ្វើការសម្រុះសម្រួល មិនអាចយកមកនិយាយគ្នានាពេលក្រោយនៅក្នុងសវនាការយុត្តិធម៌ ឬនៅក្នុងតុលាការបានឡើយ ។

## 10. តើខ្ញុំអាចស្នើសុំសវនាការយុត្តិធម៌បានដោយរបៀបណា?

អ្នកក៏អាចស្នើសុំសវនាការយុត្តិធម៌ស្តីពីវិវាទរបស់អ្នកជាមួយនឹង DOR ជំនួសឲ្យ ឬក៏បន្ថែមពីលើការស្វែងរកដំណោះស្រាយតាមការសម្រុះសម្រួល បានដែរ ។ អ្នកត្រូវដាក់ពាក្យស្នើសុំសវនាការយុត្តិធម៌ ក្នុងរវាងមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលអ្នកទទួលបានលិខិតជូនដំណឹងចំណាត់ការសកម្មភាព ឬក៏សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលអ្នកមិនយល់ស្របជាមួយ ។ ច្បាប់ Title 9 CCR §7354(a)(1) ។ ដូចអ្វីដែលបានបញ្ជាក់ពីខាងលើស្រាប់ បើអ្នកស្វែងរកដំណោះស្រាយវិវាទ តាមបែបរដ្ឋបាល គឺអ្នកត្រូវដាក់ពាក្យស្នើសុំសវនាការយុត្តិធម៌ ក្នុងរវាង 30 ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចចំពោះដំណោះ ស្រាយតាមបែបរដ្ឋបាល ។

សវនាការយុត្តិធម៌ ត្រូវតែធ្វើឡើងក្នុងរវាង 60 ថ្ងៃ គិតចាប់ពីថ្ងៃដែលអ្នកបានស្នើសុំជាលាយលក្ខណ៍អក្សរ លុះត្រាតែអ្នកយល់ព្រមចំពោះការពន្យារពេល សវនា ការ ។ ច្បាប់ Title 9 CCR §7354(b) ។

ការស្នើសុំសវនាការយុត្តិធម៌ ត្រូវដាក់ស្នើដោយប្រើបែបបទ DR 107 ។ ទម្រង់បែបបទនេះ មានក្នុងអនឡាញ តាមអាសយដ្ឋាន ៖ http://www.rehab.cahwnet.gov/Appeals/FairHearForms.html#DR107 ។

## 11. តើនឹងមានអ្វីកើតឡើងនៅឯសវនាការយុត្តិធម៌?

នៅឯសវនាការយុត្តិធម៌ គឺអ្នកមានឱកាសដើម្បីបង្ហាញ និងបញ្ជាក់ភស្តុតាង ពីអ្វីដែលអ្នកទាមទារ នៅចំពោះមុខអង្គចៅក្រមច្បាប់រដ្ឋបាល (ALJ, Administrative Law Judge) ។ អ្នកអាចនាំយកឯកសារ សាក្សី ឬភស្តុតាងផ្សេងៗមកបង្ហាញ ALJ បាន ។ បណ្ដឹងឧទ្ធរណ៍ ដើម្បីស្នើសុំសវនាការយុត្តិធម៌ ដែលស្នើសុំដោយ អ្នកដាក់ពាក្យសុំ ឬអតិថិជនDOR នឹងត្រូវធ្វើឡើងដោយមន្ត្រីសវនាការមិន លំអៀងដែលមានឈ្មោះក្នុងបញ្ជីឈ្មោះ ALJs របស់នាយកដ្ឋានសេវាកម្មទូទៅ (Department of General Services) នៃការិយាល័យសវនាការរដ្ឋបាល (OAH, Office of Administrative Hearings) ។ ALJ នឹងចេញសេចក្ដីសម្រេច ក្នុងរវាង 30 ថ្ងៃក្រោយពេលសវនាការយុត្តិធម៌ត្រូវបានបញ្ចប់ ។ ច្បាប់ Title 9 CCR §7358 ។

## 12. តើ DOR អាចកាត់ផ្ដាច់សេវាកម្មដែលខ្ញុំកំពុងទទួលបានដែរឬទេ នៅពេលដែលមិនទាន់មានសេចក្ដីសម្រេច?

ទេ ។ បើដំណើរការដំណោះស្រាយវិវាទតាមបែបរដ្ឋបាល ឬបើការិយាល័យសវនាការរដ្ឋបាល (Office of Administrative Hearings) មិនទាន់ចេញសេចក្ដីសម្រេចទេ DOR មិនអាចព្យួរ កាត់បន្ថយ ឬកាត់ផ្ដាច់សេវាកម្មណាមួយដែលត្រូវបានផ្ដល់ឲ្យអ្នកក្រោម IPE បានឡើយ ។ ក្នុងនេះក៏មានការលើកលែងចំនួនពីរផងដែរ ប្រសិនបើអ្នកស្នើសុំឲ្យគេបញ្ចប់សេវាកម្មនោះតែម្ដង ឬក៏ DOR កំណត់ឃើញថាមានការបន្លំ ឬសកម្មភាពឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តិឡើងដោយសាម៉ីខ្លួន ។ ច្បាប់ Title 9 CCR §7351(e) ។

## 13. តើត្រូវធ្វើដូចម្ដេច បើខ្ញុំមិនពេញចិត្តចំពោះសេចក្ដីសម្រេចរបស់សវនាការយុត្តិធម៌?

បើអ្នកមិនពេញចិត្តចំពោះសេចក្ដីសម្រេចរបស់សវនាការយុត្តិធម៌ គឺអ្នកមានសិទ្ធិដាក់ញត្តិប្ដឹងចំពោះសេចក្ដីសម្រេចនេះ ក្នុងរវាងប្រាំមួយខែ ទៅកាន់តុលាការរដ្ឋកាលីហ្វ័រនីញ៉ា ។

## 14. តើខ្ញុំអាចស្នើសុំឲ្យសមាជិកគ្រួសារ ធ្វើជាតំណាងរូបខ្ញុំនៅឯការសម្រុះសម្រួល ឬនៅក្នុងសវនាការយុត្តិធម៌បានដែរឬទេ?

អ្នកអាចចាត់តាំងនរណាម្នាក់ ឲ្យធ្វើជាអ្នកតំណាងស្របច្បាប់ ដើម្បីតំណាងរូបអ្នកនៅក្នុងដំណើរការសម្រុះសម្រួល និងក្នុងសវនាការយុត្តិធម៌បាន ។ អ្នកអាចសុំឲ្យសមាជិកគ្រួសារ មិត្តភក្ដិ ឬអ្នកគស្លុំមតិដទៃទៀត ធ្វើជាអ្នកតំណាងស្របច្បាប់របស់អ្នក បាន ។ ជនដែលធ្វើជាអ្នកតំណាងស្របច្បាប់ ត្រូវបំពេញសំណុំបែបបទ DR 108 មុនពេលអាចធ្វើជាអ្នកតំណាងឲ្យអ្នកបាន ។

សំណុំបែបបទនេះ មាននៅឯ ៖
http://www.rehab.cahwnet.gov/Appeals/FairHearForms.html#DR107 ។

## 15. តើត្រូវធ្វើដូចម្តេច បើខ្ញុំមិនចេះភាសាអង់គ្លេស ឬក៏ពិការត្រចៀក ឬភ្នែក?

អ្នកអាចស្នើសុំឲ្យគេផ្ញើឲ្យអ្នកនូវការជូនដំណឹង និងសេចក្តីសម្រេច ជាភាសាទីមួយរបស់អ្នក ឬក៏តាមរយៈរបៀបនៃការទំនាក់ទំនងដែលអ្នកចង់បាន ។ នៅពេលអ្នកបានធ្វើការស្នើសុំជាក់លាក់ណាមួយរួចរាល់ហើយ DOR ត្រូវតែផ្តល់ឲ្យអ្នកនូវលិខិតជូនដំណឹង និងសេចក្តីសម្រេច ជាភាសាទីមួយរបស់អ្នក ឬទៅតាមរបៀបនៃការទំនាក់ទំនងដែលអ្នកចង់បាន ។ ក្រមរដ្ឋកាលីហ្វ័រនីញ៉ា Welf. & Inst. ក្រម §19013.5(a)-(b) ច្បាប់ Title 9 CCR §7352(a) ។ ក្នុងនេះផងដែរ បើអ្នកចង់ទទួលបានលិខិតជូនដំណឹង និងសេចក្តីសម្រេច ដែលសរសេរជាភាសាដទៃក្រៅពីភាសាអង់គ្លេស ការបោះពុម្ពជាអក្សរធំៗ ឬជាអក្សរសម្រាប់មនុស្សពិការភ្នែក សូមកុំភ្លេចស្នើសុំឯកសារនេះក្នុងភាសា ឬទ្រង់ទ្រាយដែលអ្នកចង់បាន ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។ អ្នកអាចស្នើសុំទទួលលិខិតជូនដំណឹងជាភាសា និង/ទ្រង់ទ្រាយផ្សេងៗ នៅពេលអ្នកដាក់ពាក្យសុំការស្វែងរកដំណោះស្រាយវិវាទតាមបែបរដ្ឋបាល ការសម្រុះសម្រួល ឬសវនាការយុត្តិធម៌ ។

## 16. តើខ្ញុំអាចស្នើសុំអ្នកបកប្រែភាសា ឬអ្នកអាន ឬការសម្រួលផ្សេងៗទៀតបានទេ នៅក្នុងពេលស្វែងរកដំណោះស្រាយតាមបែបរដ្ឋបាល ពេលសម្រុះសម្រួល ឬក្នុងសវនាការយុត្តិធម៌?

អាចស្នើសុំបាន ។ បើអ្នកមិននិយាយភាសាអង់គ្លេស ថ្លង់ ខូចត្រចៀក ពិបាកនិយាយ ងងឹតភ្នែក ឬភ្នែកពិបាកមើល គេត្រូវតែផ្តល់ឲ្យអ្នកនូវសេវាកម្មបកប្រែភាសា និងសេវាអ្នកអាន ឬផ្តល់ឲ្យអ្នកនូវឧបករណ៍ជំនួយការស្តាប់ ។ វាអាស្រ័យលើអ្នកក្នុងការស្នើសុំសេវាកម្មទាំងអស់នេះ ។ ច្បាប់ Title 9 CCR §§ 7353(c), 7353.6(c), 7354(d)(3) ។ បើអាចទៅរួច ត្រូវស្នើសុំការសម្រួល នានាទុកជាមុន ។ អ្នកអាចសុំឲ្យមានការសម្រួល នៅពេលអ្នកធ្វើការស្នើសុំរកដំណោះស្រាយសំណុំរឿងតាមបែបរដ្ឋបាល ការសម្រុះសម្រួល ឬសវនាការយុត្តិធម៌ ។

## 17. តើខ្ញុំអាចស្នើសុំមធ្យោបាយធ្វើដំណើរទៅកាន់ និងត្រឡប់មកផ្ទះវិញពីកន្លែងដោះស្រាយសំណុំរឿងតាមបែបរដ្ឋបាល កន្លែងសម្រុះសម្រួល ឬសវនាការយុត្តិធម៌ បានដែរឬទេ?

អ្នកអាចស្នើសុំ DOR ឲ្យផ្តល់មធ្យោបាយធ្វើដំណើរ ទៅកាន់កន្លែងដំណើរការដំណោះស្រាយសំណុំរឿងឡើងវិញតាមបែបរដ្ឋបាល ឬកន្លែងសម្រុះសម្រួល ។ ច្បាប់ Title 9 CCR §7353(d), 7353.6(d) ។ បើទោះបីជាបទបញ្ញត្តិ ទាំងឡាយ មិនបាន

បញ្ជាក់ច្បាស់អំពីរឿងនេះក៏ដោយ អ្នកអាចស្នើសុំ DOR សាកមើលថា តើគេអាចផ្ដល់មធ្យោបាយធ្វើដំណើរសម្រាប់ទៅកាន់កន្លែងសវនាការយុត្តិធម៌ ដែរឬទេ បើអ្នកត្រូវការ ។

សូមទាក់ទងជាមួយអ្នកតស៊ូមតិ (CAP, Client Assistance Program) របស់អ្នកតាមលេខ 800-776-5746 ដើម្បីស្នើសុំជំនួយ ។ អ្នកតស៊ូមតិ CAP ប្រហែលអាចជួយអ្នកបាន ក្នុងការដោះ ស្រាយបញ្ហារបស់អ្នក ជាមួយនឹង DOR ។

*Disability Rights California បានទទួលថវិកាឧបត្ថម្ភពីប្រភពផ្តល់ជំនួយមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html ។*